ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ២៤៨១/២២ អអរ

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី «ស្ថានភាពនៃការជួញដូរមនុស្ស នៅកម្ពុជា»

ព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី «ស្ថានភាពនៃការជួញដូរមនុស្ស នៅកម្ពុជា» ដែលមានវាគ្មិនចូលរួមគឺៈ

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស
- លោកជំទាវនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកឧត្តម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌
- ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការ ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
- លោក ចាន់ សារ៉ុន ប្រធានកម្មវិធីជាន់ខ្ពស់ នៃអង្គការសម្ព័ន្ធចាប់ដៃ
- មេធាវី សេក សារឿន ប្រធានផ្នែកច្បាប់ និងគោលនយោបាយ នៃអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)
- លោក កេង ប៊ុនឈឿត នាយកប្រចាំតំបន់អាស៊ី នៃអង្គការ ERIKSHJALPEN ( ERIKS )

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ ឆ្លើយតបឱ្យទាន់សភាពការណ៍ដែលសហរដ្ឋអាមេរិក បានសរសេរក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការជួញដូរមនុស្សនៅលើពិភពលោករបស់ក្រសួងការបរទេសអាមេរិក ដែលដាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ៣ ស្មើនឹងកម្ពុជា មិនបានធ្វើអ្វីសោះដែលជារឿងមិនពិត ជាហេតុផលនៃការដាក់ទណ្ឌកម្មថែមទៀត គឺជារឿងអយុត្តិធម៌មិនអាចទទួលយកបាន។ កន្លងមករាជរដ្ឋាភិបាល ដៃគូជាតិ និងអន្តរជាតិបានដឹងច្បាស់អំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទទួលលទ្ធផលជាច្រើន។

## I. សេចក្តីផ្តើម

អំពើជួញដូរមនុស្ស គឺជាវិបត្តិសកលមួយដែលបណ្តាប្រទេសជាច្រើនបានជួបប្រទះ។ ប្រទេសកម្ពុជា ក៏បានទទួលរងនូវវិបត្តិនេះ ដែលធ្វើឱ្យរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋទាំងអស់មានការព្រួយបារម្ភជាខ្លាំង។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាល ក៏ដូចជាដៃគូសហការទាំងអស់ ជាពិសេសអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ បាននិងកំពុងខិតខំប្រឹងប្រែងរិះរកគ្រប់វិធានការ ក្នុងន័យរួមគ្នាដោះស្រាយលើបញ្ហានេះ ឈានទៅសម្រេចបាននូវការលុបបំបាត់នូវអំពើជួញដូរមនុស្ស ព្រមទាំងបានរៀបចំនូវយន្តការការពារទៅលើប្រជាពលរដ្ឋទូទៅ ពលករ ធុរកិច្ចជន ភ្ញៀវជាតិ និងអន្តរជាតិគ្រប់និន្នាការទាំងអស់ ដោយមិនប្រកាន់នូវជាតិ សាសនាអ្វីទាំងអស់ សំដៅប្រែក្លាយទៅជាប្រទេសដែលមានសុខសុវត្ថិភាព។

## II. យន្តការក្នុងការប្រយុទ្ធប្រឆាំង

រាជរដ្ឋាភិបាល បានបន្តរៀបចំ និងកែប្រែទៅលើយន្តការជាតិជាបន្តបន្ទាប់ ដើម្បីជាការឆ្លើយតបទៅនឹងការវិវត្តនៃកលល្បិចរបស់ឧក្រិដ្ឋជន ដែលយន្តការជាតិនោះ មានលក្ខណៈទូលំទូលាយ។ ក្នុងឆ្នាំ២០១៤ រាជរដ្ឋាភិបាល បានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ២២ និងមានអង្គភាពជំនាញសំខាន់ៗ ចំនួន៥ បានចូលរួម រួមទាំងមានអង្គការក្រៅរាជរដ្ឋាភិបាលជាដៃគូផងដែរ។

យុទ្ធសាស្ត្រអនុវត្តកន្លងមក របស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រួមមាន៖ ការបង្ការ ទប់ស្កាត់, កិច្ចការពារជនរងគ្រោះ, យុត្តិធម៌ព្រហ្មទណ្ឌ(ការផ្តន្ទាទោស), និងកិច្ចសហប្រតិបត្តិការ ក្នុងការរៀបចំ អនុវត្តច្បាប់ និងបានបង្កើតក្រុមការងារចំនួន៦ សម្រាប់ការអនុវត្តមានដូចជា ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា, ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយស្នងការដ្ឋាននគរបាលជាតិ, ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ក្រុមការងារទេសន្តប្រវេសន៍ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយក្រសួងកិច្ចការនារី ដែលក្រុមការងារទាំងអស់ តែងតែមានអង្គការក្រៅរាជរដ្ឋាភិបាល សហការជានិច្ច។ ជាមួយគ្នានេះ ដើម្បីជំរុញប្រសិទ្ធភាពក្នុងការងារនេះ រាជរដ្ឋាភិបាល បានពង្រីកវិសាលភាពដល់ថ្នាក់ក្រោមជាតិ ដែលរួមមាន៖ គណៈកម្មាធិការរាជធានី-ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអគ្គលេខាធិការដ្ឋាន ដែលជួយគាំទ្រគណៈកម្មាធិការ

ជាតិ សម្របសម្រួលដឹកនាំ ការងារប្រចាំថ្ងៃ ទំនាក់ទំនង តាមដាន ត្រួតពិនិត្យ ប្រមូល ចងក្រងរបាយការណ៍ ព្រមទាំងមានរចនាសម្ព័ន្ធដល់ថ្នាក់ ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ ទូទាំងប្រទេស។

## III. ស្ថានភាពនៃការជួញដូរមនុស្ស

អំពើជួញដូរមនុស្ស ងាយកើតឡើងទៅលើប្រជាពលរដ្ឋដែលបានធ្វើទេសន្តរប្រវេសន៍ទៅក្រៅប្រទេសដោយពុំមានឯកសារផ្លូវច្បាប់គ្រប់គ្រាន់ គឺងាយនឹងទទួលរងនូវការកេងប្រវ័ញ្ច ធ្វើបាប គៀបសង្កត់។ នៅក្នុងឆ្នាំ២០២១ ការបង្ក្រាបបទល្មើសបានចំនួន ៣៥៩ករណី សង្គ្រោះប្រជាពលរដ្ឋបានចំនួន ១៥៧៧នាក់ បានបញ្ជូនទៅតុលាការចំនួន ៥៣៨ករណី ដែលចំនួននេះ មានការកើនឡើង បើធៀបនឹងឆ្នាំ២០១៩ គឺមានត្រឹម ១៥៥ករណី សង្គ្រោះប្រជាជនបានចំនួន ៤៦៧នាក់ប៉ុណ្ណោះ។ គ.ជ.ប.ជ បានខិតខំប្រឹងប្រែងប្រយុទ្ធនឹងបញ្ហានេះ ដោយខិតខំបង្កើនការចុះអប់រំ ផ្សព្វផ្សាយ នៅតាមបណ្តាមូលដ្ឋានមានចំនួនជាង ១២ម៉ឺនលើក ដើម្បីបញ្ជ្រាបការយល់ដឹងអំពីបញ្ហាជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋទាំងអស់ ព្រមទាំងបាននិងកំពុងរៀបចំនូវផែនការប្រតិបត្តិការពិសេស សម្រាប់ស្រាវជ្រាវ និងបង្ក្រាបទៅលើករណីជួញដូរមនុស្ស ដែលមានលើទឹកដីកម្ពុជាផងដែរ។

## IV. ទិសដៅការងារបន្ត

គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងស្ថាប័នពាក់ព័ន្ធ បានដាក់ចេញនូវទិសដៅការងារសំខាន់ៗមួយចំនួន ដើម្បីបន្តទប់ស្កាត់ និងបង្ការអំពើជួញដូរមនុស្សឱ្យកាន់តែល្អប្រសើរឡើង រួមមាន៖

- ពង្រឹកការរៀបចំនូវផែនការសកម្មភាពការងារ ដោយផ្តោតសំខាន់ទៅលើបញ្ហាដែលប្រឈម
- បន្តជំរុញការអនុវត្តគោលនយោបាយសុខភាពទេសន្តរប្រវេសន៍ របស់ក្រសួងសុខាភិបាល ដោយគិតគូអំពីសុខភាពជាចម្បង
- បន្តជំរុញឱ្យមានកម្មវិធីផ្សព្វផ្សាយ អប់រំ ប្រជាពលរដ្ឋពីថ្នាក់ជាតិ ដល់ថ្នាក់មូលដ្ឋាន និងវគ្គបណ្តុះបណ្តាលទៅលើមន្ត្រីអនុវត្ត ដើម្បីបង្កើននូវប្រសិទ្ធភាពការងារ
- បន្តកែលម្អនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសពាក់ព័ន្ធ ដើម្បីឈានទៅសម្រេចបាននូវកិច្ចព្រមព្រៀង ក្នុងការអនុវត្តច្បាប់ បង្កលក្ខណៈងាយស្រួល ក្នុងការបង្ក្រាបនូវអំពើជួញដូរមនុស្ស ដែលជាប្រភេទបទល្មើសឆ្លងដែននេះ។